# អដ្ឋង្គិកមគ្គ
## គឺធម៌ប្រៀបបាននឹងផ្លូវដ៏ប្រសើរ ៨ យ៉ាង

*(បទពាក្យ ៧)*

*អដ្ឋង្គិកមគ្គ ជាក់ជាផ្លូវ នាំយើងឆ្ពោះទៅរកនិព្វាន*
*មានអង្គប្រាំបីប្រើជាយាន ជាស្ពានចម្លងអស់សព្វសត្វ ។*
*រីអង្គប្រាំបីចែកជា ខន្ធ រក្សាប្រកាន់ត្រូវប្រយ័ត្ន*
*១ គឺ សីលខន្ធ កុំឲ្យបាត់ សំអិតដុសខាត់រៀងរាល់ថ្ងៃ ។*
*២ គឺ សមាធិខន្ធ សុខស្ងប់ រំលត់រម្ងាប់គ្រឿងចង្រៃ*
*ធ្វើចិត្តឲ្យកើតសុខប្រពៃ អស់ព្រួយអស់ភ័យក្នុងសន្តាន ។*
*៣ គឺ បញ្ញាខន្ធ ភ្លឺថ្លា យល់ឃើញពិចារណាច្បាស់ក្នុងប្រាណ*
*ឃើញសច្ចៈបួនដ៏ចំណាន លែងចង់បំពានបៀតបៀនគេ ។*
*សីលខន្ធ បែកមែកចែកជាបី គួរជនប្រុសស្រីប្រុងរិះរេ*
*១ សម្មាវាចា កុំភូតគេ កុំចាក់ចុចជេរស្តីមួលកាច់ ។*
*២ គឺ សម្មាកម្មន្តោ ចៀសវាងធ្វើចោរសម្លាប់ផ្តាច់*
*៣ សម្មាអាជីវោ ធម៌ចាំបាច់ រកស៊ីល្អល្អាច់មិនបោកប្រាស់ ។*
*សម្មាធិខន្ធ មានបីខ ១ សម្មាវាយាមោ ចាំឲ្យច្បាស់*
*២ សម្មាសតិ នឹងល្អណាស់ មិនគិតប្តូរផ្លាស់គេឯងអញ ។*

៣ សម្មាសមាធិ ប្រឹងសង្រួម លះបង់អាសវៈខំផ្ចាលផ្ចាញ់
ងងឹតបាត់ទៅពន្លឺចេញ ឃើញបញ្ញាពេញឥតសង្ស័យ ។
វី **បញ្ញាខន្ធ** មានពីរខ គួរចាំឲ្យល្អរៀងរាល់ថ្ងៃ
១ សម្មាទិដ្ឋិ ឃើញប្រពៃ បានដល់អរិយសច្ចៈបួន ។
២ គឺ សម្មាសង្កប្បៈ ត្រិះរិះឃើញជាក់ត្រូវប្រុងខ្លួន
លះកាមសាងផ្នួសដោយសមសួន មិនគិតគុំគួនឬព្យាបាទ ។
សម្មាវាចា ពោលដោយល្អិត ចៀសវចីទុច្ចរិតបួនជាអាទិ៍
**មុសា-បេសុញ្ញ-ផរុសវាទ** សម្ផប្បលាប ពាក្យរោយរាយ ។
**មុសាវាទ** កុំពោលកុហក មិនពិតអាក្រក់កុំនិយាយ
**បេសុញ្ញវាទ** ញុះញង់វាយ ប្រហារទម្លាយពាក្យចាក់ដោត ។
**ផរុសវាទ** ជេរប្រទេច ផ្តាសាពាក្យពេចន៍យ៉ាងគ្រាតគ្រោត
**សម្ផប្បលាបវាទ** មិនចូលសោត មិនមានប្រយោជន៍ពាក្យឥតន័យ។
**សម្មាកម្មន្តោ** ការងារល្អ ចៀសវាងនូវកាយទុច្ចរិតបី
បាណាអទិន្នាទានចង្រៃ នាំនូវទុក្ខភ័យដល់សព្វសត្វ ។
**បាណាតិបាត** ផ្តាច់ជីវិត សម្លាប់ឥតគិតសែនរន្ធត់
**អទិន្នាទាន** លួចប្លន់សម្លុត បំផ្លាញរោលដុតនូវទ្រព្យធន ។

**កាមេ** ប្រព្រឹត្តខុសក្នុងកាម បំពានសីលធម៌សែនទារុណ
រំលោភបង្ខំសេពមេថុន ប្តីកូនប្រពន្ធអ្នកដទៃ ។
**សម្មាអាជីវោ** គិតរកស៊ី ជួញដូរមូលមីដោយប្រពៃ
មិនឆបោកប្រាស់ផ្លាស់សម្តី បន្លំក្រឡៀសាងទុច្ចរិត ។
វៀរចាកអាជីវៈដែលឲ្យទោស ដែលខុសច្បាប់រដ្ឋបានបញ្ញត្ត
មិនយូរមិនឆាប់ជួបវិបត្តិ ជីវភាពខ្វាយខ្វាត់បាត់មង្គល ។
ចៀសវាងជំនួញប្រាំប្រការ ដែលនាំទោសាឲ្យអំពល់
នាំអស់អ្នកផងកើតកង្វល់ បង្កើតចលាចលក្នុងសង្គម ។
១ គឺ **សត្ថវណិជ្ជា** ជួញសស្ត្រាវុធតូចមធ្យម
គ្រឿងចាក់គ្រឿងកាប់គ្រឿងវាយដំ កាំភ្លើងតូចធំបាញ់ប្រហារ ។
២ គឺ **សត្តវណិជ្ជា** ជួញដូរលក់មនុស្សគ្មានមេត្តា
ប្រើជាទាសីឬពេស្យា ប្រមាថមនុស្សាឥតប្រណី ។
៣ គឺ **មំសវណិជ្ជា** ជួញដូរមំសាសត្វស្រុកព្រៃ
បង្កើតបាណាបាបចង្រៃ សម្លាប់ប្រល័យផ្តាច់ជីវិត ។
៤ គឺ **មជ្ជវណិជ្ជា** ជួញគ្រឿងសុរាមេរ័យពិត
វង្វេងសតិលង់គំនិត ឲ្យចុះកេរ្តិ៍កិត្តិយសធ្លាក់ ។

**៥ គឺ វិសទណវិជ្ជា** ជួញគ្រឿងពិសពុលនាំញ៉ាំញញ្ជាក់
ជួញប្រាំប្រការបានបញ្ជាក់ ហួរហែជាក់លាក់សព្វគ្មានសល់។
**សម្មាវាយាម** ត្រៀមប្រុងខ្លួន ប្រកបអង្គបួនព្យាយាមខ្វល់
១ មើលរវាំងបាបអកុសល កុំឲ្យកើតដល់ក្នុងសន្តាន ។
២ ខំលះបាបដែលមាននោះ ជម្រុះឲ្យអស់ពីក្នុងប្រាណ
៣ រកកុសលបុណ្យឲ្យបាន ភាវនាបឆានទុកប្រចាំ ។
៤ រក្សាបុណ្យដែលមានហើយ កុំប្រហែសឡើយឲ្យប្រេះស្រាំ
របូតជ្រុះធ្លាក់ក្នុងភក់ជ្រាំ ព្យាយាមថែទាំតរៀងទៅ ។
**សម្មាសតិ** ការភ្ញាក់នឹក គិតគូររព្ញកដល់ជម្រៅ
**សតិប្បដ្ឋាន** បួនជាទិសដៅ នាំទៅឲ្យកើតជាបញ្ញា ។
ឃើញកាយវេទនាចិត្តនិងធម៌ មិនមានញាប់ញ័រក្នុងកាយា
ឃើញកាយក្នុងកាយជាធម្មតា វេទនាយ៉ាំងណាក៏យ៉ាំងនោះ ។
ឃើញចិត្តក្នុងចិត្តធម៌ក្នុងធម៌ គ្មានគិតរីករវខឹងប្រទូស្ត
គ្រាន់តែវេទនាចិត្តប៉ុណ្ណោះ មិនមែនសត្វមនុស្សយើងគេឡើយ។
**សម្មាសមាធិ** ចម្រើនឈាន ចិត្តស្ងប់នឹងនួនកើតឡើងហើយ
**អប្បនាសមាធិ** ជាចម្លើយ មិនយឺតយូរឡើយនឹងកើតឈាន។

បឋមជ្ឈាន មានអង្គប្រាំ　　**វិតក្កៈ វិចារៈ បីតិ** មាន
សុខឯកគ្គតា ជាប្រធាន　　ដែលមានក្នុងឈានដំបូងគេ ។
ពេលអស់ វិត្តកៈ វិចារៈ　　ចូលដល់ទុតិយជ្ឈាន ពុំរេ
ពេលនេះនៅសល់តែបីទេ　　បីតិ សុខេ ឯកគ្គតា ។
បើលះបីតិចោលទៅទៀត　　ចូលតតិយជ្ឈាន ជាសញ្ញា
ចុងក្រោយលះបង់ចោលសុខា　　សល់តែឯកគ្គតា ទីបំផុត ។
ឈានចុងក្រោយគឺឧបេក្ខា　　និងឯកគ្គតា ហៅចតុត្ថ-
ជ្ឈានមួយសម្រេចយ៉ាងមោះមុត　　តាំងចិត្តបរិសុទ្ធយ៉ាងប្រពៃ ។
**សម្មាទិដ្ឋិ** យល់ត្រង់ផ្លូវ　　បញ្ញាឃើញត្រូវក្នុងអរិយ-
សច្ចៈបួនយ៉ាងឥតសង្ស័យ　　ច្បាស់ក្នុងអរិយសច្ចធម៌ ។
សច្ចទីមួយគឺ **ទុក្ខសច្ច**　　មិនអាចប្រកែកថាភូតភរ
មានរូបមានទុក្ខភ័យញាប់ញ័រ　　ទោះមានឬក្រគេចមិនរួច ។
**សមុទយសច្ច** មេនៃទុក្ខ　　ប្រភពជង្រុកនាំផ្ដើមផ្ដួច
កិលេសតណ្ហាមានមុខស្រួច　　រុញច្រានបក់គួចឲ្យសាងកម្ម ។
**និរោធសច្ច** ផ្ដាច់រំលត់　　នាំចេញឲ្យផុតពីក្រញាំ
លះបង់កាត់ផ្ដាច់ហេតុដែលនាំ　　ឲ្យកើតទុក្ខធំក្នុងសន្ដាន ។

**និរោធគាមិនីបដិបទា** ឧត្តមមាគ៌ាឆ្ពោះនិព្វាន
**អដ្ឋង្គិកមគ្គ** *ប្រើជាយាន នាំសត្វដល់ឋានក្សាន្តផុតទុក្ខ ។*
**សម្មាសង្កប្បៈ** *ការត្រិះរិះ ប្រពៃវិសេសមានបីមុខ*
*ត្រិះរិះចាកកាមទៅរកសុខ កសាផ្នួសទុកលះតណ្ហា ។*
*ត្រិះរិះទីពីរមិនព្យាបាទ ព្យាយាមសង្វាតផ្សាយមេត្តា*
*ដល់មនុស្សឬសត្វគ្រប់ទិសា មិនថានៅមុខឬកំបាំង ។*
*ត្រិះរិះទីបីមិនបៀនបៀត ករុណាសព្វសត្វជាទីតាំង*
*មានចិត្តប្រណីដល់កម្លាំង កុំប្រឹងបង្ខំប្រើតែផ្ដាស ។*
*ចូរដើរតាមផ្លូវគឺអរិយមគ្គ ជាផ្លូវល្អជាក់ប្រសើរណាស់*
*ក្រៅផុតពីផ្លូវនេះមិនច្បាស់ សេនាមារប្រាសភ័យភ័ន្តភាំង ។*
*បើអ្នកដើរតាមផ្លូវនេះបាន ទុក្ខទាំងប៉ុន្មានរីងគោកគាំង*
*ខ្ញុំគ្រាន់តែប្រាប់ផ្លូវកំបាំង សរមានពិសខ្លាំងបានដកចេញ។*
*អ្នកដុតកិលេសជាបន្ទាន់ ផ្លូវនេះខ្ញុំគ្រាន់តែប្រាប់មិញ*
*អ្នកប្រឹងប្រតិបត្តិដុតចម្រាញ់ អាចចេញរួចពីចំណងមារ ។*
*កាលមានបញ្ញាឃើញច្បាស់ថា សង្ខារមិនទៀងគ្រប់វេលា*
*នឿយណាយធុញទ្រាន់នឹងទុក្ខា នោះគឺមាគ៌ាល្អបរិសុទ្ធ ។*

កាលមានបញ្ញាឃើញច្បាស់ថា    រាល់គ្រប់សង្ខារទុក្ខបំផុត
នឿយណាយនឹងទុក្ខយ៉ាងមោះមុត    ផ្លូវនោះបរិសុទ្ធផុតអន្តរាយ ។
កាលមានបញ្ញាឃើញច្បាស់ថា    គ្រប់តែសង្ខារតែងបែកធ្លាយ
គឺអនត្តាគួរនឿយណាយ    ផ្លូវដែលរីករាយមគ្គប្រាំបី ។
កាលខ្លួននៅក្មេងវ័យអាចអង់    បែរជាលះបង់សព្វករណីយ៍
សិក្សារៀនសូត្រសព្វអ្វី ៗ    អាស្រ័យភាពខ្ជិលជាកត្តា ។
ការខ្ជិលលះបង់ភាពព្យាយាម    ខ្ជិលនាំទីមទាមទោសទុក្ខា
អ្នកខ្ជិលមិនបានផ្លូវថ្លៃថ្លា    គឺផ្លូវបញ្ញាផុតទុក្ខភ័យ ។
រក្សាវាចាបានត្រឹមត្រូវ    ចិត្តសង្រួមត្រូវល្អប្រពៃ
កាយកម្មជាទោសទោះចាស់ថ្មី    ធ្វើមិនគប្បីលះឲ្យបាន ។
កម្មបថបីយ៉ាងបានបរិសុទ្ធ    ព្យាយាមបំផុតក្នុងសន្តាន
រីករាយក្នុងមគ្គទៅកាន់ឋាន    ដែលព្រះទ្រង់ញាណទេសនាប្រាប់
យោគាវចរខំភាវនា    កើតមានបញ្ញាយ៉ាងគួរគាប់
លះការភាវនាសែនអភ័ព្វ    បញ្ញាមានស្រាប់ក៏អស់ទៅ ។
បណ្ឌិតស្គាល់នូវផ្លូវទាំងពីរ    ចម្រើនវិនាសការតាំងនៅ
តម្កល់ស្មារតីលើផ្លូវត្រូវ    ឋិតនៅលើផ្លូវកើនបញ្ញា ។
ចូរកាប់ឆ្ការព្រៃគឺកិលេស    កុំចេះតែកាប់ព្រៃធម្មតា

ភ័យតែងកើតមានពីតណ្ហា ភិក្ខុកាត់ព្រៃណាលុះត្រាគ្មាន ។
កាលព្រៃតណ្ហាមិនដាច់បង់ នៃប្រុសឆ្ពោះត្រង់ស្រីនៅមាន
តិចតួចយ៉ាងណាជាមូលដ្ឋាន ឲ្យបានជំពាក់វែងអន្លាយ ។
ប្រៀបបានកូនគោនៅបៅដោះ ចិត្តកូនគោនោះជាប់នឹងម្ដាយ
កូនគោទោះដើរទៅជិតឆ្ងាយ តែងរត់រកម្ដាយបៅរអាហារ ។
អ្នកត្រូវលះកាត់ក្ដីស្រឡាញ់ ក្នុងខ្លួនអ្នកចេញពិធីណា
ដកផ្កាឈូកសក្នុងជលសា ដោយផ្ទាល់ហត្ថានាសារទៈ ។
ចូរអ្នកដើរតាមផ្លូវត្រូវស្ងប់ ឲ្យចម្រើនគ្រប់ប្រាំបីដាក់
ព្រះសុគតទេសន៍សន្តិមគ្គ ដល់ពួកសាវ័កគឺនិព្វាន ។
ជនពាលគិតថាអញបិតនៅ អស់មួយរដូវទីនេះបាន
ផុតក្ដៅរងាររភ្លៀងស្រាកស្រាន មិនបានដឹងភ័យអន្តរាយជាក់ ។
មច្ចុទាញយកជនដែលជាប់ នឹងកូនឬទ្រព្យសត្វពាហនៈ
ប្រៀបបានជំនន់ធំបានធ្លាក់ គួចយកពួកអ្នកស្រុកលក់ស្កប់ ។
ពេលស្លាប់មកដល់រកការពារ បុត្រភ្ញាបិតាសំឡាញ់សព្វ
ក្នុងចំណោមញាតិជួយតទប់ ពំនឹងទាំងគ្រប់មិនមានន័យ ។
បណ្ឌិតបានដឹងហេតុនោះជាក់ សង្រួមគារវៈសីលថ្លាថ្លៃ
ដើរតាមអង្គមគ្គទាំងប្រាំបី ឆាប់ក្រៃឆ្ពោះត្រើយនិព្វានហោង៕